## កម្រៃសេវា

| កម្រិតសហគ្រាស | កម្រៃសេវា (រៀល) |
| --- | --- |
| សិប្បកម្ម (ធុនមីក្រូ) (ដើមទុនតិចជាង ឬដល់៥ម៉ឺនដុល្លារ) | ១៥០,០០០ |
| សហគ្រាសធុនតូច (ដើមទុនលើសពី ៥ម៉ឺនដុល្លារ ដល់៥០ម៉ឺនដុល្លារ) | ៣០០,០០០ |
| សហគ្រាសធុនមធ្យម (ដើមទុនលើសពី ៥០ម៉ឺនដុល្លារ ដល់១លានដុល្លារ) | ៥០០,០០០ |

## ទម្រង់ប្រកាសរបស់ក្រសួង ឧ.វ.ប.ន.


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

ប្រកាស

## ព័ត៌មានផ្សេងៗ

អាសយដ្ឋាន ៖ ច្រកចេញចូលតែមួយនៃក្រសួង ឧ.វ.ប.ន.
#៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ព័ត៌មាន និងជំនួយបន្ថែម សូមស្កេនចូលតេឡេក្រាម៖

https://t.me/msmesupport

## គេហទំព័រ




https://msmes.misti.gov.kh

www.registrationservices.gov.kh

វិបសាយដែលមានសារៈសំខាន់ចំពោះ SMEs ដទៃទៀត ៖

https://misti.gov.kh/
https://www.khmersme.gov.kh/



# ស្នើសុំប្រកាស

## បង្កើតសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម

SMEs & Handicraft Establishment Service

## តាមប្រព័ន្ធអនឡាញ-Online Registration



## តើអាជីវកម្មប្រភេទណាដែលត្រូវស្នើសុំប្រកាសបង្កើត សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ?

យោងតាមច្បាប់លេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម បានកំណត់ថារាល់សហគ្រាសធុនតូច និងមធ្យមនិងសិប្បកម្ម ក្នុងវិស័យកម្មន្តសាលតម្រូវឱ្យស្នើសុំប្រកាសបង្កើតសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម។

ប្រកាសបង្កើតសហគ្រាសធុនតូននិងមធ្យម និងសិប្បកម្ម សំដៅដល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ឱ្យអ្នកស្នើសុំអាចបង្កើតសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម ដែលមានដើមទុនស្មើឬតិចជាង១លានដុល្លារ និងមានទម្រង់ជាការផលិត កែច្នៃ វេចខ្ចប់ បង្គុំ ។ល។

ប្រកាសបង្កើតតាមថ្នាលបច្ចេកវិទ្យា ពីក្រសួង ឧ.វ.ប.ន. មានត្រឹមតែ ប្រាំមួយ(៦)ជំហាន និង ចំណាយពេលត្រឹមតែបី(៣)ថ្ងៃប៉ុណ្ណោះ

# ៦ជំហានប៉ុណ្ណោះ ត្រឹមរយៈពេល៣ថ្ងៃ

**STEP 01**
ចុះឈ្មោះតាមរយៈគេហទំព័រ
www.registrationservices.gov.kh

**STEP 02**
ចុច «អាជ្ញាបណ្ណជំនាញ» រួចជ្រើសរើស «ក្រសួងឧ.វ.ប.ន.»

**STEP 03**
ស្កេន QR Code លើ Portal ដោយប្រើប្រាស់កម្មវិធីទូរស័ព្ទ CamDigiKey ឬប្រើប្រាស់ username និង password

**STEP 04**
បំពេញព័ត៌មាន និងភ្ជាប់ឯកសារចាំបាច់ រួចដាក់ស្នើ

**STEP 05**
បង់កម្រៃសេវាតាមមធ្យោបាយទូទាត់ប្រាក់អនឡាញ

**STEP 06**
ទាញយកនិងបោះពុម្ពប្រកាសឌីជីថលក្រោយការអនុម័ត

## ដំណើរការនៃការបំពេញពាក្យស្នើសុំប្រកាសបង្កើតនៅលើផ្ទាំងស្នើសុំរបស់ក្រសួងឧ.វ.ប.ន.

**អ្នកស្នើសុំតម្រូវឱ្យបំពេញព័ត៌មានដូចខាងក្រោម៖**

១. ព័ត៌មានអំពីពាក្យសុំបង្កើត
២. អ្នកគ្រប់គ្រង
៣. ព័ត៌មានវត្ថុធាតុដើម
៤. គ្រឿងចក្រ និងបរិក្ខារផលិតកម្ម
៥. កាកសំណល់ផលិតកម្ម
៦. សេចក្តីប្រកាស (ការយល់ព្រម)
៧. ហត្ថលេខា
៨. បង់ប្រាក់

